បំពាក់ "តាមគំរូ ដែលតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល ។

**ប្រការ ៥ :** ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ឬល្មើសប្រការណាមួយដែលបានចែងខាងលើ ប្រកាសនេះនឹង ត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

**ពូ សុធីរ:**

* * *

## ៣ - ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

## ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មិថុនា ឆ្នាំ ១៩៩៦

### ប្រកាសលេខ ០០២៩/៩៦ កព.ប្រក

### ស្តីពីការបង្កើតក្រុមបញ្ជូនឯកសាររបស់ក្រុមការងារពិសេស

ប្រធានក្រុមការងារពិសេស

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ វរ្ម័ន** ព្រះចៅក្រុងកម្ពុជាធិបតី ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា ។
- បានឃើញសេចក្តីសំរេចលេខ ៨៧ សសរ. ចុះថ្ងៃទី ២៣ ខែ ធ្នូ ឆ្នាំ ១៩៩៥ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតក្រុមការងារពិសេស សំរាប់ធ្វើការវាយបក ឆ្លើយតបចំពោះការផ្សាយ ពត៌មានបង្ខូចពីរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ។
- យោងតាមតម្រូវការនិងភារកិច្ចចាំបាច់ ។

## សំរេច

**ប្រការ ១ :** បង្កើតក្រុមបញ្ជូនឯកសាររបស់ក្រុមការងារពិសេស ដែលមានសមាសភាព :

១_ឯកឧត្តម **ព្រាប ញាណវិចិត្រ** អនុរដ្ឋលេខាធិការនៃក្រសួងពត៌មាន ប្រធាន

២_លោក **ឡេង សុជា** អគ្គនាយករងរដ្ឋបាលនិងហិរញ្ញវត្ថុនៃក្រសួងពត៌មាន អនុប្រធាន

៣_លោក **ម៉ុត មុខ្ទុត** អគ្គនាយករង អា. កា. ប៉េ នៃក្រសួងពត៌មាន សមាជិកអចិន្ត្រៃយ៍

៤_លោក **មួង សុវត្ថិ** ប្រធាននាយកដ្ឋានមណ្ឌលពត៌មាននៃក្រសួងពត៌មាន សមាជិក

៥_លោក **ជុំ សារុំ** ប្រធានការិយាល័យទីស្តីការក្រសួងពត៌មាន សមាជិក

**ប្រការ ២** : ក្រុមបញ្ជូនឯកសារ របស់ក្រុមការងារពិសេសនេះមានភារកិច្ច :

- បញ្ជូនឯកសាររាជរដ្ឋាភិបាលទៅគ្រប់ក្រសួងស្ថាប័ន ខេត្ត-ក្រុងក្នុងប្រទេស
- បញ្ជូនឯកសារ រាជរដ្ឋាភិបាលទៅបណ្តាស្ថានទូត ស្ថានបេសកកម្មការទូត អង្គការអន្តរជាតិ និងអង្គការក្រៅរដ្ឋាភិបាលដែលប្រចាំនៅក្នុងព្រះរាជាណាចក្រកម្ពុជា ដែលនៅក្រៅប្រទេស ។

**ប្រការ ៣** : ថវិកាចំណាយរាល់ការរៀបចំ និងបញ្ជូនឯកសារ គឺបន្ទុកចំណាយរបស់ក្រុមការងារពិសេស ។

**ប្រការ ៤** : សមាជិកក្រុមការងារពិសេស ផ្នែករដ្ឋបាល និងហិរញ្ញវត្ថុរបស់ក្រុមការងារពិសេស និងសាមីខ្លួនក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីប្រកាសនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ប្រធានក្រុមការងារពិសេស

ហត្ថលេខា និង ត្រា

**ខៀវ ភាញារិទ្ធ**

* * *